# Long Beach Unified School District

## មន្ទីរអប់រំឡុងប៊ីច

### សាលា Hi Hill នៅ មណ្ឌលបោះជំរំ YMCA Camp Oakes

## សៀវភៅព័ត៌មាន សំរាប់គ្រួសារ
## 2025 - 2026

### កម្មវិធីបោះជំរំសិក្សាក្រៅសាលា សំរាប់ថ្នាក់ទី 5

YMCA Camp Oakes
Big Bear City, CA

# មាតិការ


**លិខិតពីអគ្គនាយកមន្ទីរអប់រំ…....................................................................................................................... 3**

**សេចក្តីសង្ខេបអំពីដំណើរបោះជំរំសិក្សាទៅកាន់ សាលា Hi Hill នៅជំរំ Camp Oakes.......................................... 4**

**ព័ត៌មានទូទៅអំពីមណ្ឌលបោះជំរំ សាលា Hi Hill នៅ Camp Oakes............................................................... 5 - 7**

**គោលការណ៍ច្បាប់ និងនិតិវិធីបោះជំរំ LBUSD នៅ Camp Oakes……………………………………………... 8 - 10**

**បញ្ជីត្រួតពិនិត្យ មុននឹងបោះជំរំសិក្សា………………………………………………………………………...…11-12**

Office of the Superintendent
1515 Hughes Way, Long Beach, CA 90810
(562) 997-8242

ខែឧសភា ឆ្នាំ2023

ជូនចំពោះក្រុមគ្រួសារនៃសិស្សថ្នាក់បឋមសិក្សា និង K-8 ជាទីគោរព៖

ខ្ញុំមានសេចក្តីសោមនស្សរីករាយសូមជំរាបជូនលោកអ្នកថា ជាផ្នែកមួយនៃកម្មវិធីសិក្សារបស់មន្ទីរអប់រំ ឡុងប៊ីច សិស្សរៀនថ្នាក់ទីប្រាំទាំងអស់នឹងមានឱកាសចូលរួមក្នុងកម្មវិធីអប់រំផ្នែកខាងក្រៅសាលា រយៈពេលពេញមួយសប្តាហ៍នៅ Camp Oakes ដែលស្ថិតនៅក្បែរក្រុង Big Bear នៃរដ្ឋកាលីហ្វ័រញ៉ា និងចាប់ផ្តើមក្នុងរដូវស្លឹកឈើជ្រុះ ក្នុងឆ្នាំ2023 នេះ។  ការធ្វើដំណើរសិក្សាទាំងអស់នេះ នឹងបន្តទំនៀមទំលាប់ ដែលបានចាប់ផ្តើមធ្វើនៅក្នុងមន្ទីរអប់រំរបស់យើង តាំងងពីខែមេសា ឆ្នាំ1948 មក ដោយមានសិស្សទៅចូលរួមក្នុងការបោះជំរំសិក្សា នៅសាលា Hi-Hill ជារៀងរាល់ឆ្នាំ។  ជាអកុសល គឺកម្មវិធីបោះជំរំសិក្សានេះត្រូវបានបិទចោល។ ខ្ញុំមានសេចក្តីរីករាយ ដែលនាពេលថ្មីៗនេះ គណៈកម្មការអប់រំរបស់យើង បានធ្វើការអនុម័តបង្កើតកម្មវិធី អប់រំនៅខាងក្រៅសាលានេះឡើងវិញ ដោយប្រើប្រាស់បរិក្ខារនិងអាគារបោះជំរំរបស់មណ្ឌល YMCA នៅ Camp Oakes ។

ការរៀបចំសំរាប់ដំណើរទស្សនកិច្ចសិក្សាខាងក្រៅសាលានេះ ដោយរាប់បញ្ចូលទាំងការរៀបចំដឹកជញ្ជូនតាមឡាន ប៊ីស នឹងត្រូវបានចាត់ចែង និងឧបត្ថមថវិកាដោយការិយាល័យកណ្តាល ប៉ុន្តែ លោកអ្នក នឹងបានស្នើសុំឱ្យផ្តល់ជាព័ត៌មានចុះឈ្មោះដែលត្រូវការចាំបាច់ ដើម្បីធានាឱ្យមានការរៀបចំដំណើរឱ្យបានត្រឹមត្រូវសំរាប់សិស្សរបស់លោកអ្នក។  សាលារៀននីមួយៗ នឹងត្រូវដាក់កាលវិភាគឱ្យចូលរួមតាមកាលបរិច្ឆេទខុសៗគ្នានៅទូទាំងឆ្នាំសិក្សាទាំងមូល ដូច្នេះហើយ កូនសៀវភៅណែនាំអំពីការបោះជំរំសិក្សានៅសាលា Hi Hill នៅមណ្ឌលបោះជំរំ YMCA Camp Oakes សំរាប់គ្រួសារនេះ ត្រូវបានចងក្រងឡើង ដើម្បីធានានូវបទពិសោធន៍ដ៏ល្អសំរាប់សិស្ស គ្រូបង្រៀន និងបុគ្គលិក LBUSD ទាំងឡាយ ដែលចូលរួមក្នុងទស្សនកិច្ចសិក្សាទាំងនេះ។ ដោយមានការជួយជ្រោមជ្រែងពីលោកអ្នក គឺខ្ញុំប្រាកដក្នុងចិត្តថា ដំណើរទស្សនកិច្ចសិក្សារយៈពេលពេញមួយសប្តាហ៍នៅលើភ្នំ នឹងបន្តផ្តល់នូវបទពិសោធន៍ដ៏មានអត្ថន័យសំរាប់សិស្សថ្នាក់ទីប្រាំរបស់យើង ដែលលើកកម្ពស់ដល់ចំណេះផ្នែកធម្មជាតិ និងវិទ្យាសាស្រ្ត ព្រមទាំងជួយកសាងជំនាញក្នុងការទំនាក់ទំនងសង្គម និងគុណតម្លៃផ្ទាល់ខ្លួនល្អផងដែរ។

ប្រសិនបើលោកអ្នកមានសំណួរ ឬក្តីកង្វល់អ្វី សូមទាក់ទងទៅកាន់លោក Jeff Wood ដែលជានាយកគ្រប់គ្រងកម្មវិធីអប់រំផ្នែកខាងក្រៅសាលា នៅការិយាល័យ កម្មវិធីពង្រីកឱកាសរៀនសូត្រ តាមលេខទូរសព្ទ (562) 997-8000 ហើយបន្តទៅលេខ 447-7680 ឬ អ៊ីម៉ែល jwoo@lbschools.net។

ដោយក្តីស្មោះស្ម័គ្រ

Jill A. Baker, Ed.D
អគ្គនាយក

# ការសិក្សានៅខាងក្រៅ នៅសាលា Hi Hill នៅជំរំ YMCA Camp Oakes
## សេចក្តីសង្ខេបអំពីការធ្វើដំណើរសិក្សា

**<u>គោលបំណង</u>**
ដំណើរទស្សនកិច្ចសិក្សាសំរាប់សិស្សថ្នាក់ទី5 ទៅកាន់សាលា Hi Hill នៅជំរំ Camp Oakes ត្រូវបានអនុវត្តតាមផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់មន្ទីរអប់រំឡុងប៊ីច ដើម្បីផ្តល់ឱកាសស្មើភាពគ្នាដល់យុវវ័យ ក្នុងការស្វែងយល់អំពីពិភពផ្សេងទៀត លើសពីសហគមន៍របស់ពួកគេ។ ឱកាសនេះផ្តល់ជាឱកាសក្នុងការសិក្សា នៅខាងក្រៅរយៈពេលមួយសប្តាហ៍ សំរាប់សិស្សថ្នាក់ទី5គ្រប់រូប។ ការស្រាវជ្រាវបានបញ្ជាក់ថា កម្មវិធីសិក្សា នៅខាងក្រៅពិតជាមានប្រយោជន៍ តាមទ្រង់ទ្រាយផ្សេងៗជាច្រើន។ វាអាចជួយបង្កើនទំនុកចិត្តផ្ទាល់ខ្លួន គុណតម្លៃផ្ទាល់ខ្លួន ជំនាញទំនាក់ទំនងសង្គម ការប្រាស្រ័យទាក់ទង ការជម្រុញលើកទឹកចិត្ត និងជំនាញកាយសម្បទា ដែលជួយឱ្យមានឥរិយាបថល្អក្នុងការសិក្សា និងបង្កើនសមត្ថភាពមនុស្សឱ្យបំពេញកិច្ចការដោយភាពសហការណ៍។

**<u>តើសិស្សនឹងសិក្សាអំពីអ្វី</u>**
សាលា Hi Hill នៅជំរំ YMCA Camp Oakes ផ្តល់ជាឱកាសសិក្សាពិសេសដល់កុមារឱ្យជួប និងរាក់ទាក់យ៉ាងចុះសំរុងជាមួយមនុស្សមកពីមជ្ឈដ្ឋានផ្សេងៗ ដែលនឹងបានជាប្រយោជន៍ដល់ពួកគេ ក្នុងការសិក្សានៅតាមសាលារៀន និងនៅទូទាំងជីវិតរបស់ពួកគេ។ ការរស់នៅក្នុង បរិស្ថានដែលសិក្សានៅខាងក្រៅ រយៈពេល 24ម៉ោង ក្នុងមួយថ្ងៃ គឺសិស្សនឹងមានឱកាសជាច្រើនក្នុងការបង្កើនការយល់ដឹង និងបណ្តុះទឹកចិត្ត នៃការមានគោលដៅតាមរយៈស្ថានការជីវិតជាក់ស្តែង។ នៅ Hi Hill នៅជំរំ YMCA Camp Oakes គឺសិស្សទទួលបន្ទុកនូវទំនួលខុសត្រូវថ្មីៗ ចេះគោរព និងមានអំណរចំពោះចំណងមិត្តភាពរបស់មិត្តរួមថ្នាក់ និងគ្រូបង្រៀនរបស់ពួកគេ ដោយឆ្លងកាត់បទពិសោធន៍ជាច្រើន នៅក្នុង សម្រស់ដ៏ត្រកាល និងភាពដ៏អស្ចារ្យនៃធម្មជាតិខាងក្រៅ។ សិស្សនឹងហាត់ប្រើជំនាញទំនាក់ទំនងល្អៗ ការគ្រប់គ្រងខ្លួនឯង និងបង្កើនផ្នត់គំនិត ក្នុងការរីកលូតលាស់របស់ពួកគេ ដោយឆ្លងកាត់ការរស់នៅប្រចាំថ្ងៃ ដោយមានការយកចិត្តទុកដាក់ចំពោះមនុស្សដទៃ និងការថែទាំខ្លួនផ្ទាល់របស់ពួកគេ។

នៅក្នុងកម្មវិធីបោះជំរំសិក្សាខាងក្រៅ គឺសិស្សរៀនយល់ផ្ទាល់តែម្តងអំពីគោលគំនិតផ្នែកវិទ្យាសាស្ត្រ ដូចជា៖ ទេសភាព រុក្ខជាតិ និងសត្វព្រៃ ភូគព្ភសាស្ត្រ ថ្មដា និងរ៉ែ ហ្វូងផ្កាយ រុក្ខសាស្ត្រ អាកាសធាតុ ដំណើរការបំផ្លែងទឹក ហើយនិងគោលគំនិតផ្នែកវិទ្យាសាស្ត្រ និងជំនាញទំនាក់ទំនង សង្គម ដោយឆ្លងកាត់ឱកាសសិក្សាដែលដកពិសោធន៍ផ្ទាល់។ កម្មវិធីសិក្សាដែលត្រូវបានបង្ហាត់ គឺជាចំណែកដ៏សំខាន់មួយនៃបទពិសោធន៍ សិក្សាផ្នែកវិទ្យាសាស្ត្ររបស់កូនលោកអ្នក។ កម្មវិធីសិក្សានៅខាងក្រៅ នាំសិស្សចេញពីក្នុងថ្នាក់រៀន ទៅក្នុងថ្នាក់រៀនតាមរបៀបប្លែកៗផ្សេងពីគ្នា ដែលសិស្សសិក្សាអំពីអ្វីៗគ្រប់យ៉ាង ដោយអនុវត្ត និងដកពិសោធន៍ ផ្ទាល់ដៃ។ កម្មវិធីសិក្សានៅខាងក្រៅ ផ្តល់បទពិសោធន៍សិក្សាដ៏រំភើប និងរីករាយ សំរាប់សិស្ស។ ដូច្នេះហើយ សិស្សរៀនឆាប់ចេះជាង យល់ដឹងល្អជាង និង ចងចាំបានកាន់តែច្រើនអំពីអ្វីដែលពួកគេសិក្សា។

សាលា Hi Hill នៅជំរំ YMCA Camp Oakes គឺមានសកម្មភាពជាច្រើនសំរាប់សិស្ស ដែលរាប់បញ្ចូលដូចជា៖ បាញ់ធ្នូ គំនូរ និងសិប្បកម្ម ស្គូចត្រី ល្បែងជាក្រុម លេងបាល់ទះ ការស្រាវជ្រាវរុករកធម្មជាតិ ការដើរក្នុងព្រៃភ្នំ ជិះទូកកានូ លេងបាល់ហ្គាហ្គា តោងឡើងភ្នំថ្ម ប្រកួត តោងខ្សែពួកពីសទាបៗ ការអង្កេតនិងសម្លឹងមើលហ្វូងផ្កាយ កម្មវិធីជួបជុំគ្នាក្បែរភ្នក់ភ្លើង អមដោយការច្រៀងលេង ហើយនិងរឿងកំប្លែងខ្លីៗ និងសកម្មភាពជាច្រើនផ្សេងទៀត។ សកម្មភាពទាំងអស់នេះ នឹងជួយសិស្សបង្កើនចំណេះរបស់ពួកគេ ជំរុញពួកគេឱ្យចេះធ្វើការតស៊ូ និង រៀនសិក្សារួមជាមួយគ្នានៅក្នុងធម្មជាតិដ៏អស្ចារ្យខាងក្រៅ ។

មានឪពុកម្តាយ និងជីដូនជីតាជាច្រើន ដែលបានរៀននៅតាមសាលាបឋមសិក្សាក្នុង LBUSD នៅតែនឹកចងចាំយ៉ាងច្បាស់លាស់ អំពីការចំណាយពេលពេញមួយសប្តាហ៍ចូលរួមក្នុងកម្មវិធីសិក្សានៅខាងក្រៅ ហើយយើងដឹងថា កូនៗរបស់លោកអ្នក ក៏នឹងចងចាំដូច្នោះដែរ។

# កម្មវិធីសិក្សានៅខាងក្រៅនៅ Hi Hill នៅជំរំ YMCA Camp Oakes
# ព័ត៌មានទូទៅ

**ទីតាំងបរិក្ខារនិងអាគារបោះជំរំ**

កម្មវិធីសិក្សានៅខាងក្រៅរបស់មន្ទីរអប់រំ ឡុងប៊ីច គឺស្ថិតនៅ Long Beach YMCA’ s Camp Oakes លើខ្នងភ្នំ San Bernardino ក្បែរក្រុង Big Bear។ វាស្ថិតនៅលើផ្ទៃដីប្រមាណ 235អា ក្នុងឧទ្យានជាតិ San Bernardino National Forest ដែលមានកំពស់ 7,200 ហ្វីត។ ជំរំ Camp Oakes មានចម្ងាយប្រមាណ 120 ម៉ាយ ពីក្រុង Long Beach ឬ បើកបររយៈពេល 15នាទី ពីក្រុង Big Bear។

**តម្លៃចំណាយ**

Hi Hill នៅ YMCA Camp Oakes គឺឧបត្ថមថវិកាទាំងស្រុងដោយមន្ទីរអប់រំ ឡុងប៊ីច។ **គ្មានត្រូវបង់ថ្លៃអ្វីឡើយសំរាប់ទៅចូលរួម**។ ក្រុមគ្រួសារទទួលខុសត្រូវក្នុងការផ្គត់ផ្គង់សំលៀកបំពាក់ និងប្រដាប់ប្រដាគេងឱ្យបានសមរម្យសំរាប់កូនៗរបស់ពួកគេ។ ក្រុមគ្រួសារណាដែលត្រូវការសំលៀកបំពាក់ ឬប្រដាប់ប្រដាគេង គួរទាក់ទងទៅកាន់លោក Jeff Wood ដែលជានាយកគ្រប់គ្រងកម្មវិធីអប់រំនៅខាងក្រៅប្រចាំ LBUSD តាមអ៊ីម៉ែល jwood@lbschools.net ឬ នាយកសាលារបស់ពួកគេ ដើម្បីពិគ្រោះអំពីតម្រូវការរបស់ខ្លួន។

**ការដឹកជញ្ជូន**

មន្ទីរអប់រំ ឡុងប៊ីច នឹងផ្តល់នូវការដឹកជញ្ជូនតាមឡាន ប៊ីស ទៅមកពី Hi Hill នៅជំរំ YMCA Camp Oakes នៅថ្ងៃចេញដំណើរពីសាលារៀន និងថ្ងៃត្រឡប់មកវិញ ដោយគ្មានគិតថ្លៃចំណាយឡើយ។ ***បើមានមូលហេតុណាមួយដែលតំរូវឱ្យសិស្សត្រឡប់ទៅផ្ទះវិញក្នុងសប្តាហ៍ដែលកំពុងនៅជំរំ គឺមាតាបិតាត្រូវតែទៅទទួលសិស្សពីជំរំ ដោយបង់ថ្លៃចំណាយដោយខ្លួនឯង។***

**ការទទួលស្គាល់កន្លែងបោះជំរំ**

ជំរំ YMCA Camp Oakes ត្រូវបានទទួលស្គាល់ជាផ្លូវការដោយ (American Camp Association/សមាគមជំរំអាមេរិក) ដែលមានន័យថា វាជាកន្លែង ដែលគេពិនិត្យវាយតម្លៃ ដើម្បីអនុវត្តតាមស្តង់ដាសុខភាព និងសុវត្ថិភាពជាង 300ផ្នែក ដែលរៀបចំចងក្រងដោយអ្នកជំនាញការមកពីវិស័យជាច្រើន ដូចជា៖ ការគ្រប់គ្រងផ្នែកហានិភ័យ ការអភិវឌ្ឍកុមារ អ្វីដែលដុះនិងរស់នៅក្នុងទឹក និងការថែទាំសុខភាព។ មន្ទីរសុខាភិបាលប្រចាំ San Bernardino ខោនធី និងការិយាល័យផ្សេងៗរបស់ ខោនធី/រដ្ឋ ក៏បានធ្វើការត្រួតពិនិត្យមើលកន្លែងបោះជំរំនោះផងដែរ ដូចដែលបានកំណត់ដោយច្បាប់។

**ការចាត់ចែងការប៊ីនស្នាក់នៅ**

គ្រូៗរបស់សិស្សទាំងអស់ នឹងបង្កើតជាក្រុមស្នាក់នៅកាប៊ីនទៅតាមភេទសិស្ស មុនពេលចេញដំណើរ។ គ្រូនឹងព្យាយាមយ៉ាងអស់ពីលទ្ធភាព ដើម្បីដាក់មិត្តរួមថ្នាក់របស់សិស្សយ៉ាងហោចណាស់ចំនួនម្នាក់ ឱ្យស្នាក់នៅក្នុងកាប៊ីនជាមួយគ្នា ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏គ្មានការធានាថា មិត្តទាំងអស់នឹងនៅជុំគ្នានោះទេ។ កាប៊ីនស្នាក់នៅ នឹងមានសិស្សមកពីថ្នាក់រៀនផ្សេងៗ ឬមកពីសាលារៀនផ្សេងៗរបស់ LBUSD ដែលទៅចូលរួមក្នុងសប្តាហ៍ជាមួយគ្នានោះដែរ ជាការផ្តល់ឱកាសដល់សិស្ស ដើម្បីរាប់អានមិត្តថ្មីៗ។

**ការគ្រប់គ្រងកាប៊ីនស្នាក់នៅ**

ក្រុមស្នាក់នៅតាមកាប៊ីនទាំងអស់ នឹងត្រូវបានគ្រប់គ្រងដោយអ្នកប្រឹក្សាជាមនុស្សពេញវ័យ ដោយមានចំនួនសមាមាត្រដែលស្របតាមលក្ខខណ្ឌទាមទារ របស់សមាគមបោះជំរំសហរដ្ឋអាមេរិក។ បុគ្គលិកទាំងអស់នឹងត្រូវបានជ្រើសរើស ទៅតាមលទ្ធភាពរបស់ពួកគេក្នុងការធ្វើការជាមួយក្មេងៗ និងឆ្លងកាត់ឆ្លងកាត់វគ្គបណ្តុះបណ្តាលបុគ្គលិកយ៉ាងទូលំទូលាយ មុនសប្តាហ៍នៃការអប់រំសិក្សានៅខាងក្រៅរបស់សិស្ស។ បុគ្គលិកដឹកនាំការបោះជំរំ ជាអ្នកប្រកបដោយវិជ្ជាជីវៈដែលមានការលះបង់ខ្ពស់ ដោយមានបទពិសោធន៍ធ្វើការជាមួយក្មេងៗនៅជំរំអស់រយៈពេលជាច្រើនឆ្នាំ។ បុគ្គលិក YMCA Camp Oakes និង LBUSD ទាំងអស់ជាអ្នករាយការណ៍ដែលកំណត់ដោយច្បាប់។

**ការរំលោភបំពានលើកុមារ**
បុគ្គលិកមន្ទីរអប់រំ LBUSD ត្រូវបានកំណត់ដោយច្បាប់ឱ្យរាយការណ៍ភ្លាមៗទៅកាន់អជ្ញាធរសមស្រប រាល់ករណីសង្ស័យ អំពីការរំលោភបំពានលើកុមារ (រួមមានទាំង ការរំលោភបំពានលើរាងកាយ លើផ្លូវចិត្ត ឬដោយពាក្យសម្តី និង/ឬ ការមិនយកចិត្តទុកដាក់ចំពោះកុមារ)។

**ជំងឺនឹកផ្ទះ**
ការនៅឆ្ងាយពីផ្ទះរយៈពេលមួយសប្តាហ៍ អាចជាបទពិសោធន៍ដ៏លំបាកចំពោះកុមារគ្រប់វ័យទាំងអស់។ នៅពេលកុមារស្ថិតនៅឆ្ងាយពីផ្ទះជាលើកដំបូង ពួកគេប្រហែលជានឹកផ្ទះហើយ។ យើងសូមឱ្យលោកអ្នកជួយពិគ្រោះពន្យល់ដល់កូនរបស់អ្នក មុននឹងទៅបោះជំរំ។ និយាយប្រាប់ពួកគេថា លោកអ្នកមានទំនុកចិត្តលើសមត្ថភាពរបស់ពួកគេ ក្នុងការសម្របខ្លួនជាមួយបទពិសោធន៍ថ្មីៗនៅជំរំ។ ផ្តោតការយកចិត្តទុកដាក់លើចំណុចល្អៗនៃការការបោះជំរំ ដូចជា ការរាប់អានមិត្តថ្មីៗ សកម្មភាពដែលពួកគេនឹងចូលរួមសប្បាយ និងការកោតសរសើរពីលោកអ្នកនៅពេលដែលពួកគេបានទទួលជោគជ័យ។ នៅពេលទៅដល់កន្លែងបោះជំរំ បុគ្គលិកនឹងប្រើវិធីសាស្ត្រព្យាបាលជំងឺនឹកផ្ទះដ៏ល្អបំផុត ដែលគេស្គាល់ថា ដោយធ្វើឱ្យសិស្សមានការមមាញឹកនិងសប្បាយៗ។ យើងខ្ញុំលើកទឹកចិត្តឱ្យមានការផ្ញើសំបុត្រពីផ្ទះ។ សំបុត្រលើកទឹកចិត្តល្អៗមកពីផ្ទះ ធ្វើឱ្យកូនរបស់លោកអ្នកទទួលដំណឹងពីលោកអ្នក តាមរបៀបកែលម្អដែលលើកទឹកចិត្តដល់កូន។ សូមចងចាំថា ជំរំ Camp Oakes បាននាំមកជាបទពិសោធន៍ដ៏ល្អៗដល់សិស្សរាប់ពាន់នាក់អស់ជាច្រើនឆ្នាំកន្លងមក ហើយយើងដឹងថា វានឹងផ្តល់បទពិសោធន៍ដូច្នោះដែរសំរាប់កូនរបស់លោកអ្នក។

**ការត្រៀមរៀបចំសំរាប់បោះជំរំ**
ការបោះជំរំ ជាការរំភើបសប្បាយ និងជាឱកាសសំរាប់កូនរបស់លោកអ្នកក្នុងការកសាងគុណម្លៃផ្ទាល់ខ្លួន និងបង្កើតនូវជំនាញទំនាក់ទំនងផ្ទាល់ខ្លួន។ នេះក៏ជាកន្លែងដែលអាចរៀនសូត្រអំពីឯករាជ្យភាព និងការទទួលខុសត្រូវផងដែរ។ សិស្សនឹងថែទាំខ្លួន រៀបចំកន្លែងគេង និងថែរក្សាអីវ៉ាន់របស់ខ្លួន។ នៅផ្ទះ គឺយើងសូមលើកទឹកចិត្តដល់មាតាបិតា ដោយទុកឱ្យសិស្សរៀបចំអីវ៉ាន់ដោយខ្លួនឯង និងវេចខ្ចប់ដោយរៀបតាម ***បញ្ជីត្រួតពិនិត្យសំរាប់សិស្ស មុននឹងចេញដំណើរ***។ ការធ្វើដូច្នេះ កូនរបស់លោកអ្នកអាចចាប់ផ្តើមរៀន អំពីរបៀបចាត់ចែងដោយខ្លួនគេ ហើយក៏ជួយឱ្យពួកគេមានទឹកចិត្តរំភើបសប្បាយ អំពីកាបោះជំរំផងដែរ។ សិស្សមិនអាចខ្ចប់យកចំណី និង/ឬ គ្រាប់ស្ករទៅជាមួយបានទេ។ សូមជួយជ្រោមជ្រែង និងផ្តោតទៅលើលអ្វីថ្មីៗនិងល្អៗ ដែលនឹងកើតមានឡើង។ សូមឱ្យប្រាកដថា លោកអ្នក និងកូនផ្តោតការយកចិត្តទុកដាក់ទៅលើរបស់របរដែល**មិន**ឱ្យយកទៅកន្លែងបោះជំរំ Camp Oakes មានដូចជា៖

**របស់ប្រើប្រាស់ដែលមិនអនុញ្ញាតិ - កុំយកទៅជាមួយ!**

- គ្រឿង អេឡិចត្រូនិច **គ្រប់ប្រភេទ** ដូចជា៖
  - ទូរស័ព្ទដៃ ឬ ឧបករណ៍ប្រាស្រ័យទំនាក់ទំនងផ្សេងៗ
  - កំព្យូទ័រឡេបថប ថេប្លិត iPod Earbuds ឬ នាឡិកា Smart Watch
  - ឧបករណ៍ ហ្គេម សំរាប់កាន់លេង

- ដែកកេះ ឬ កាំជ្រួច
- កាំបិត ឬ កូនពូថៅដៃ
- កាំភ្លើង
- ផលិតផលថ្នាំជក់
- ថ្នាំញៀនខុសច្បាប់
- ចំណី

- ស្ករកៅស៊ូ ឬ គ្រាប់ស្ករ
- ថ្នាំបាញ់មានជាតិ អ៊ែរូសូល

ចំពោះរបស់ប្រើប្រាស់ទាំងឡាយណាដែលមិនអនុញ្ញាតិយកទៅជាមួយ គឺនឹងត្រូវដកហូតទុក ដោយមានសរសេរឈ្មោះកូនរបស់លោកអ្នកនៅពីលើ និងរក្សាទុកនៅក្នុងការិយាល័យជំរំ រហូតដល់ថ្ងៃចេញដំណើរត្រឡប់ទៅផ្ទះវិញ។ របស់ដែលបានដកហូតទុកទាំងឡាយ នឹងត្រូវប្រគល់ឱ្យវិញ តាមការសមស្រប ឱ្យទៅបគ្គលិកសាលា ឬឪពុកម្តាយនៅពេលត្រឡប់មកពីជំរំវិញ។ LBUSD និង/ឬ YMCA មិនទទួលខុសត្រូវចំពោះរបស់របរដែលបាត់បង់ ឬបាក់បែកឡើយ នៅក្នុងដំណើរការបោះជំរំនេះ។

## ព័ត៌មានទាក់ទងសំរាប់ សាលា Hi Hill នៅជំរំ YMCA Camp Oakes

**<u>មធ្យោបាយរក្សាទំនាក់ទំនងជាមួយកូនរបស់លោកអ្នក</u>**

គ្រួសារត្រូវបានស្វាគមន៍ឱ្យផ្ញើរសំបុត្រទៅសួរសុខទុក្ខកូន នៅពេលពួកគេកំពុងស្នាក់នៅជំរំ។ សិស្ស សប្បាយចិត្តនឹងបានសំបុត្រសួរសុខទុក្ខ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ សូមមេត្តាកុំរៀបរាប់អំពីបញ្ហាក្នុងផ្ទះ ឬការនឹករលឹកចំពោះសិស្សពីអ្នកផ្ទះឱ្យសោះ។ សូមរក្សាភាពវិជ្ជមាន។ ការផ្ញើសំបុត្រ មុនដល់ថ្ងៃចេញដំណើរ នឹងធានាថា កូនរបស់លោកអ្នកពិតជាបានទទួលសំបុត្រនៅក្នុងសប្តាហ៍នោះ។ ការផ្ញើសំបុត្រ ឬប៉ុស្តិ៍កាត ក្នុងស្រោមសំបុត្រ ដោយមានបិទតែមប្រៃសណីយ៍និងអាសយដ្ឋានជាមុន គឺបង្កើនឱកាសរបស់អ្នកក្នុងការទទួលបានសំបុត្រពីសិស្សរបស់លោកអ្នកវិញ។ សូមចាំទុកថា ពេលវេលានៅឯជំរំ ដើរយឺតជាងពេលវេលានៅឯទីក្រុង។ ដូច្នេះ សូមទុកពេល 4ថ្ងៃ សំរាប់ការបញ្ជូនសំបុត្រទៅនិងមកពីផ្ទះ។ សូម**កុំ**ផ្ញើកញ្ចប់ដែលមានអាហារ ឬគ្រាប់ស្ករទៅជាមួយឱ្យសោះ។ ជំរំ Camp Oakes ស្ថិតនៅលើភ្នំ ហើយអាហារគឺធុំក្លិន និងធ្វើឱ្យសត្វល្អិតៗ និងសត្វព្រៃចង់មករកស៊ី។

យើងខ្ញុំសូមជូនជាយោបល់ដល់មាតាបិតា ឱ្យប្រគល់សំបុត្រសួរសុខទុក្ខទៅគ្រូប្រងៀនប្រចាំថ្នាក់ មុនពេលចេញដំណើរ។ គ្រូបង្រៀន នឹងចែកសំបុត្រឱ្យសិស្សក្នុងពេលស្រស់ស្រូបអាហារពេលព្រឹក នៅក្នុងសប្តាហ៍នោះ។

សូមផ្ញើសំបុត្រទៅកាន់អាសយដ្ឋានដូចតទៅ៖

**<u>បើផ្ញើតាម ប្រៃសណីយ៍សហរដ្ឋអាមេរិក៖</u>**

*ជំរំ YMCA Camp Oakes*
*ឈ្មោះរបស់សិស្ស និង ខែ-ថ្ងៃ-ឆ្នាំ ស្នាក់នៅជំរំ*
*P.O. Box 452*
*Big Bear City, CA 92314*

**<u>បើផ្ញើតាម UPS ឬ Fed Ex៖</u>**

*ជំរំ YMCA Camp Oakes*
*ឈ្មោះរបស់សិស្ស និង ខែ-ថ្ងៃ-ឆ្នាំ ស្នាក់នៅជំរំ*
*47400 Monte Vista Drive*
*Big Bear City, CA 92314*

# គោលការណ៍ច្បាប់ និង នីតិវិធីរបស់ សាលា Hi Hill នៅជំរំ YMCA Camp Oakes

**<u>ការប្រើប្រាស់ថ្នាំនៅជំរំ</u>**

**កុំ**ខ្ចប់ថ្នាំយកទៅជាមួយក្នុងវ៉ាលីរបស់សិស្ស រួមទាំងថ្នាំមិនត្រូវការវេជ្ជបញ្ជាដែរ។

**ថ្នាំទាំងអស់ (មានវេជ្ជបញ្ជា និង ថ្នាំមិនត្រូវការវេជ្ជបញ្ជា) និងឯកសារដែលតម្រូវឱ្យមាន ត្រូវតែដាក់ជូនគិលានុបដ្ឋាយិកា សាលា ឱ្យបានយ៉ាងហោចណាស់មួយសប្តាហ៍មុនពេលចេញដំណើរ។**

គិលានុបដ្ឋាយិកា នឹងត្រួតពិនិត្យថ្នាំទាំងអស់ និង ទម្រង់ឯកសារចុះឈ្មោះតាមប្រព័ន្ធអនឡាញ។ ប្រសិនបើកូនរបស់លោកអ្នក ត្រូវការថ្នាំក្នុងកំឡុងពេលនៅជំរំ ថ្នាំនីមួយៗត្រូវតែជា «ថ្នាំនៅសាលារៀន» ដែលទម្រង់បែបបទត្រូវបំពេញដោយវេជ្ជបណ្ឌិតរបស់សិស្ស។ ថ្នាំទាំងនេះរាប់ទាំងថ្នាំ មិនត្រូវការវេជ្ជបញ្ជាផងដែរ។ ថ្នាំដែលមានវេជ្ជបញ្ជាត្រូវតែមានដបថ្នាំរបស់ឪសថដ្ឋានដែលបិទផ្លាកឈ្មោះសិស្សលើដប និងការណែនាំរបស់វេជ្ជបណ្ឌិត យ៉ាងច្បាស់លាស់។ ថ្នាំដែលមិនត្រូវការវេជ្ជបញ្ជាទាំងអស់ ត្រូវតែជាដបដាក់ថ្នាំដើមរបស់វាដោយមានដាក់ឈ្មោះរបស់សិស្ស។ **<u>ថ្នាំអ្វីក៏ដោយ (រួមទាំង វីតាមីនផង) គឺមិនត្រូវអនុញ្ញាតឱ្យទុកនៅក្នុងកាប៊ីនស្នាក់នៅឡើយ</u>**៖ គិលានុបដ្ឋាយិការបស់ជំរំនឹងគ្រប់គ្រងលើការប្រើប្រាស់ថ្នាំទាំងអស់។ សូមផ្តល់ថ្នាំ ដែលអាចប្រើប្រាស់រយៈពេល 10ថ្ងៃ ដើម្បីឱ្យយើងរៀបចំត្រៀមសំរាប់ស្ថានភាដែលអាចកើតមានណាមួយ (អាកាសធាតុមិនល្អ ។ល។) សូមជួបជាមួយគិលានុបដ្ឋាយិកាសាលារបស់លោកអ្នក សំរាប់ទម្រង់បែបបទថ្នាំពេទ្យនៅសាលា (Medication at School form) និងសំណួរផ្សេងៗ។

**<u>ទូរសព្ទដៃ/ការប្រាស្រ័យទាក់ទងជាមួយសិស្ស</u>**

សូមរក្សាទុកទូរសព្ទដៃ ថេប្លិត និងនាឡិកា smart watch គ្រប់ប្រភេទទាំងអស់នៅផ្ទះ៖ ដោយឧបករណ៍ទាំងនោះ មិនត្រូវបានអនុញ្ញាតឱ្យសិស្សប្រើនៅឯជំរំឡើយ។ ក្រុមគ្រួសារទាំងឡាយ ត្រូវបានជំរុញលើកទឹកចិត្តឱ្យធ្វើការទាក់ទងតាមការផ្ញើសំបុត្រសួរសុខទុក្ខដល់កូនរបស់ពួកគេ ដូចដែលបានជំរាបជូន មុននេះរួចមកហើយ។ ក្រុមគ្រួសារក៏អាចប្រគល់សំបុត្រសួរសុខទុក្ខ ឱ្យទៅគ្រូរបស់កូនដើម្បីទុកឱ្យសិស្សនៅជំរំផងដែរ ក្នុងករណីដែលសំបុត្រផ្ញើទៅដល់មិនទាន់ពេល។ សូមមេត្តាកុំផ្ញើអាហារ ស្ករគ្រាប់ និងអ្វីផ្សេងៗទៀត ដែលត្រូវហាមឃាត់មិនឱ្យយកទៅជាមួយឱ្យសោះ។

**<u>ការថែទាំសុខភាព</u>**

សិស្ស ដែលមានជំងឺ គឺមិនអនុញ្ញាតឱ្យចូលរួមបោះជំរំឡើយ។ បើសិស្សធ្លាក់ខ្លួនឈឺ គឺជំរំ Camp Oakes មានបន្ទប់ព្យាបាលនៅនឹងកន្លែង ដោយមានគិលានុបដ្ឋាយិការបស់ជំរំផងដែរ។ ក្នុងករណីដែលមានជំងឺ សិស្សនឹងទទួលការស្នាក់នៅក្នុងបន្ទប់ព្យាបាលសុខភាពតាមពេលវេលាដែលសមហេតុផល។ បើចាំបាច់ណាស់ គឺមាតាបិតា/អាណាព្យាបាលនឹងត្រូវបានទាក់ទងឱ្យមកយកកូនរបស់ពួកគេ។ បើសិស្សរបស់លោកអ្នកមានជំងឺមុនពេលទៅបោះជំរំ គឺគិលានុបដ្ឋាយិកា នឹងធ្វើការពិនិត្យឱ្យប្រាកដថា ពួកគេពិតជាមានសុខភាពមាំមួនគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងការធ្វើដំណើរពេញមួយសប្តាហ៍នៅលើភ្នំ ដែលពោរពេញដោយសកម្មភាពដ៏មមាញឹកនិងស្វាហាប់មែនទែននេះ។

ចំពោះសិស្សណា ដែលមានលក្ខខណ្ឌសុខភាពជាក់លាក់ ដែលរួមបញ្ចូល តែមិនកំណត់ចំពោះ ដូចជា៖ គ្រុនក្តៅចាប់ពី 100.4 អង្សាលើង ឈឺបំពងក ក្អួត រាគរូស រមាស់ស្បែកធ្ងន់ធ្ងរ មុខរបួស ឬដំបៅ និង/ឬ ចៃក្បាល (ពង ឬ ចៃរស់រវើក) គឺនឹងត្រូវដកឈ្មោះ ចេញពីការចូលរួម ដើម្បីការពារដល់សុខភាពរបស់អ្នករាល់គ្នា។

ប្រសិនបើមានភាពអាសន្ន ឬតម្រូវការពិសេសអ្វីមួយកើតឡើង គឺយើងអាចប្រើសេវាកម្ម វេជ្ជបណ្ឌិត និង គ្លីនិក នៅ Big Bear បាន។ ក្នុងហេតុការមានរងរបួសស្នាមណាមួយ កំឡុងពេលដែលនៅកន្លែងបោះជំរំ គឺយើងនឹងចាត់វិធានការចាំបាច់ ដើម្បីធ្វើការព្យាបាលឱ្យត្រឹមត្រូវ ដែលអាចមាន៖ ការព្យាបាលដោយបុគ្គលិកចំពោះរបួសតូចតាច ទូរសព្ទទៅមាតាបិតា/អាណាព្យាបាលដើម្បីសុំការណែនាំពីពួកគេ ទូរសព្ទទៅវេជ្ជបណ្ឌិតដែលព្យាបាលនៅមូលដ្ឋាន ឬធ្វើការបញ្ជូនសិស្សឱ្យទៅទទួលការព្យាបាលពីវេជ្ជបណ្ឌិត ឬមន្ទីរព្យាបាល/សង្គ្រោះបន្ទាន់។ មាតាបិតារបស់សិស្សដែលមានកំដៅក្នុងខ្លួនចាប់ពី 100.4 អង្សា ឡើងទៅ គឺនឹងត្រូវគេទាក់ទង ហើយប្រហែលជាត្រូវដកចេញពីកម្មវិធីបោះជំរំដែរ។

វាជារឿងសំខាន់ណាស់ ដែលលោកអ្នកផ្តល់ព័ត៌មានទំនាក់ទំនងក្នុងគ្រាមានអាសន្នឱ្យបានពេញលេញនិងត្រឹមត្រូវ នៅក្នុងកំឡុងពេលដំណើរការចុះឈ្មោះ។ បើលោកអ្នក នឹងធ្វើដំណើរកំសាន្តពេលរាំកង គឺសូមរៀបរាប់ព័ត៌មានលម្អិតអំពីការធ្វើដំណើរ ព្រមទាំងលេខទូរស័ព្ទ ដែលយើងអាច ទាក់ទងដល់លោកអ្នកបាន។ បើមានហេតុករណ៍រងរបួស ដែលតំរូវឱ្យមានការព្យាបាល នោះបុគ្គលិក YMCA Camp Oakes និង/ឬ បុគ្គលិក LBUSD នឹងព្យាយាមទាក់ទងដល់លោកអ្នក តែទោះជាយ៉ាងណាក៏ដោយ បើក្នុងខណៈដែលទាក់ទងទៅអាណាព្យាបាលមិនបានទេ នោះការអនុញ្ញាតក្នុងការព្យាបាល គឺត្រូវផ្តលឱ្យវេជ្ជបណ្ឌិតដែលបានរជ្រើសរើសដោយបុគ្គលិក YMCA Camp Oakes និង/ឬបុគ្គលិក LBUSD ដើម្បីផ្តល់ការព្យាបាលដល់សិស្សតាមការចាំបាច់ និងសមស្របដោយវេជ្ជបណ្ឌិតរូបនោះ។

## <u>ការធានារ៉ាប់រងផ្នែកសុខភាព</u>

ក្នុងនាមជាមាតាបិតា ឬអាណាព្យាបាល គឺលោកអ្នកទទួលខុសត្រូវលើរាល់ថ្លៃព្យាបាល ដែលកើតឡើងដោយសារការរងរបួស ឬជំងឺ នៅពេលដែលកូនរបស់លោកអ្នកនៅជំរំ។ ចំពោះគ្រួសារ ដែលគ្មានធានារ៉ាប់រងផ្នែកសុខភាព គឺត្រូវបានលើកទឹកចិត្តឱ្យចូលមើលគេហទំព័រ www.CoveredCA.com ឯចំពោះគ្រួសារដែលចង់ធ្វើការជ្រើសរើសយកការធានារ៉ាប់រងផ្នែកគ្រោះថ្នាក់សំរាប់សិស្ស ដោយចេញថ្លៃចំណាយពីមាតាបិតាផ្ទាល់ គឺគួរអានអំពីគោលគារណ៍ច្បាប់របស់ LBUSD សំរាប់មាតាបិតា និងសិស្ស។ ខ្ញុំយល់ថា មន្ទីរអប់រំ គ្មានការធានារ៉ាប់រងដែលចំណាយលើថ្លៃព្យាបាល ឬចំណាយលើថ្លៃសំរាកព្យាបាលនៅមន្ទីរពេទ្យទាំងនោះសំរាប់កូនរបស់ខ្ញុំឡើយ ហេតុដូច្នេះហើយ ថ្លៃចំណាយដែលកើតឡើងសំរាប់ការព្យាបាលនោះ គឺជាការទទួលខុសត្រូវរបស់ខ្ញុំ (ឪពុកម្តាយ) ទាំងស្រុង។ សូមធ្វើយ៉ាងណាផ្តល់ផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ អំពីធានារ៉ាប់រងផ្នែកសុខភាពនៅលើ**ទម្រង់បែបបទអំពីប្រវត្តិសុខភាព។**

## <u>ការបាត់បង់ និង ការរកឃើញ</u>

បទពិសោធន៍នៃការបោះជំរំ គឺជាឱកាសសំរាប់សិស្សថ្នាក់ទី5 ដើម្បីរៀនទទួលខុសត្រូវចំពោះរបស់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេ។ សូមពិភាក្សាជាមួយសិស្សរបស់លោកអ្នក អំពីការចេះទទួលខុសត្រូវ និងការថែរក្សារបស់ប្រើប្រាស់របស់ខ្លួន។ LBUSD និង YMCA មិនទទួលខុសត្រូវទេចំពោះរបស់ប្រើប្រាស់ដែលបាត់បង់ ឬត្រូវគេលួចយកឡើយ។ <u>**កុំផ្ញើវត្ថុមានតម្លៃ**</u> ទៅជាមួយកូនរបស់លោកអ្នកឱ្យសោះ។

របស់របរប្រើប្រាស់ទាំងឡាយណាដែលបានបាត់ហើយរកឃើញវិញដោយបសមាជិគបុគ្គលិកជំរំ នឹងត្រូវដាក់តាំងបង្ហាញពេញមួយសប្តាហ៍សំរាប់ឱ្យសិស្សបោះជំរំអាចមកយកវិញបាន។ របស់របរនៅសេសសល់ ឬបានរកឃើញក្រោយពីសិស្សបោះជំរំបានចាកចេញហើយ នឹងត្រូវរក្សាទុកនៅជំរំរយៈពេលមិនឱ្យលើសពី 2សប្តាហ៍ ឡើយ។ ក្នុងនោះ គឺមានការព្យាយាមដោយសមហេតុផល ក្នុងការប្រគល់របស់ដែលបាត់និងរកឃើញនោះត្រឡប់ទៅឱ្យម្ចាស់ដើមវិញ។ សាលារៀនទាំងឡាយ នឹងត្រូវបានស្នើឱ្យជួយប្រគល់របស់ដែលបាត់និងរកឃើញនោះទៅម្ចាស់របស់នោះវិញ ប្រសិនបើរបស់របរដែលបាត់ហើយរកឃើញនោះ គ្មានអ្នកមកទាយកវិញក្នុងរយៈពេល 2សប្តាហ៍ ទេ គឺវត្ថុទាំងនោះ ប្រហែលជាត្រូវគេផ្តល់ឱ្យកន្លែងសប្បុរសធម៌ហើយ។ **សូមដាក់ឈ្មោះកូនសំគាល់នៅលើរបស់របរទាំងអស់នោះ**។

## <u>ការរំពឹងទុកអំពីវិន័យ/អាកប្បកិរិយា</u>

សិស្សទាំងអស់នឹងតំរូវឱ្យគោរពតាមវិន័យទាំងអស់របស់មន្ទីរ LBUSD វិន័យរបស់សាលានីមួយៗរៀងៗខ្លួន និងវិន័យរបស់ជំរំ YMCA Camp Oakes ចំពោះការរំពឹងទុកនូវអាកប្បកិរិយា និងសុវត្ថិភាព ដែលស្រតាមច្បាប់អប់រំផ្នែក 48900។ ដើម្បីពង្រឹងស្មារតីផ្នែកសុវត្ថិភាព និងសន្តិសុខឱ្យបានប្រសើរ គឺសិស្សនឹងចូលរួមពិភាក្សា និងរៀបចំបង្កើតជាវិន័យអាកប្បកិរិយាក្នុងការប្រព្រឹត្តនៅកន្លែងកាប៊ីនស្នាក់នៅ។ គ្រូបង្រៀន LBUSD ទាំងឡាយ និងបុគ្គលិក YMCA Camp Oakes នឹងលើកកម្ពស់ឱ្យមានអាកប្បកិរិយាល្អ តាមការយកការពង្រឹងអាកប្បកិរិយាល្អៗមកធ្វើជាគំរូ និងបច្ចេកទេសផ្សេងទៀតដែលសមរម្យទៅតាមវ័យ។
វិន័យចែងជាក់លាក់ក្នុងការបោះជំរំ នឹងត្រូវចែកឱ្យសិស្សនៅពេលទៅដល់កន្លែងបោះជំរំ។ វិន័យដ៏សំខាន់ជាងគេបំផុតគឺ៖ **1) ត្រូវរក្សាសុវត្ថិភាពឱ្យបានគ្រប់ពេលទាំងអស់** និង **2) សូមឱ្យសប្បាយរីករាយ!** សេចក្តីណែនាំក្នុងការបោះជំរំ ដែលគាំទ្រដល់វិន័យទាំងអស់នេះ គឺ៖ - ត្រូវនៅជាប់ជាមួយមនុស្សធំម្នាក់ និងសិស្សដែលចាត់តាំងជាពួកម៉ាករបស់សិស្សម្នាក់ ឱ្យបានគ្រប់ពេលទាំងអស់ បង្ហាញនូវការគោរពចំពោះមនុស្សគ្រប់រូប នៅតាមគ្រប់កន្លែងឱ្យបានគ្រប់ពេលទាំងអស់ (នេះគឺរាប់បញ្ចូលទាំងឥវ៉ាន់របស់អ្នកដ៏ទៃ យោបល់របស់អ្នកដទៃ ធម្មជាតិ សត្វព្រៃ ។ល។)។

ចំពោះបញ្ហាអាកប្បកិរិយាដែលមិនស្របតាមការរំពឹងទុក នឹងត្រូវបានទទួលការអប់រំណែនាំឡើង ដើម្បីលើកកម្ពស់ឱ្យមានអាកប្បកិរិយាល្អ ការដោះស្រាយជម្លោះ និងការប្រាស្រ័យទំនាក់ទំនងល្អជាមួយមិត្តភក្តិ តាមរយៈជំនាញប្រាស្រ័យទំនាក់ទំនងគ្នាដែលមានប្រសិទ្ធិភាព ដើម្បីបង្កើននូវគុណតម្លៃផ្ទាល់ខ្លួនរបស់កុមារ និងធានាថា សិស្សទាំងអស់អាចបានបទពិសោធន៍ល្អៗពីការបោះជំរំ។  ប្រសិនបើសិស្សបង្ហាញអាកប្បកិរិយាដែលមានបញ្ហាណាមួយនោះនឹងត្រូវចាត់វិធានការដូចខាងក្រោមនេះ៖

***ការប្រជុំជាមួយសិស្ស៖*** *ពិភាក្សាអំពីវិន័យ មូលហេតុនៃការមានវិន័យ ហើយជួយសិស្សឱ្យឆ្លុះបញ្ចាំងលើផលប៉ះពាល់នៃអំពើរបស់ពួកគេ។*

***ការឆ្លុះបញ្ចាំងរបស់សិស្ស និងអប់រំការណែនាំឡើងវិញ៖*** *អ្នកដឹកនាំកាប៊ីនស្នាក់នៅ ឬបុគ្គលិកជំរំ នឹងធ្វើការពិភាក្សាអំពីអាកប្បកិរិយានោះ ជម្រុញលើកទឹកចិត្តដល់សិស្សនោះឱ្យឆ្លុះបញ្ចាំងលើសកម្មភាពរបស់ខ្លួន និងណែនាំផ្លូវដល់សិស្សនោះឱ្យមានអកប្បកិរិយាសមរម្យ។ ជួយគាំទ្រដល់សិស្សឱ្យផ្តោតការយកចិត្តទុកដាក់លើកិរិយាមារយាទសមរម្យ ជំនួសឱ្យអាកប្បកិរិយាដែលមិនល្អនោះវិញ។ លោកគ្រូអ្នកគ្រូទាំងឡាយ នឹងត្រូវបានជូនដំណឹងអំពីស្ថានភាពនោះ និងត្រូវបានពិគ្រោះក្នុងការជួយធានាឱ្យបានលទ្ធផលវិជ្ជមាន។ លោកគ្រូអ្នកគ្រូទាំងឡាយ អាចចូលរួម និង/ឬជួយក្នុងការពិភាក្សាអំពីស្ថានភាពនោះផងដែរ។*

***សម្រួលចិត្តឱ្យត្រជាក់ និង ធ្វើការកែប្រែ -*** *បុគ្គលិកនឹងទុកពេលឱ្យសិស្សដើម្បីធ្វើការឆ្លុះបញ្ចាំលើអាកប្បកិរិយារបស់ខ្លួន ឬគ្រាន់តែ «សម្រួលចិត្តឱ្យត្រជាក់» រហូតដល់ស្ថានការធូរស្រាលនិងអាចពិភាក្សាគ្នាបានជាមួយកុមាររូបនោះ។ បុគ្គលិកនឹងជួយជ្រោមជ្រែងដល់កុមារ ក្នុងការសុំអភ័យទោស និងធ្វើឱ្យស្ថានការស្រួលបួលវិញ ឬធ្វើឱ្យអ្វីៗត្រឡប់មកសភាពដើមវាវិញ ប្រសិនបើអាចធ្វើបាន។ ឪពុកម្តាយ នឹងត្រូវគេទាក់ទង និងជូនដំណឹង អំពីស្ថានភាពនោះ។ វិធានការណ៍ទី 2។*

***ការប្រជុំជាមួយឪពុកម្តាយ -*** *បុគ្គលិកនឹងចាត់វិធានការណ៍ឱ្យបានគ្រប់លទ្ធភាពទាំងអស់ ដើម្បីដោះស្រាយអំពីអាកប្បកិរិយាសិស្សនៅឯជំរំ។ ឪពុកម្តាយរបស់សិស្សដែលបង្ហាញពីកង្វះខាតចម្លើយតប ឬទំនួលខុសត្រូវ គឺអាចទទួលបានការហៅប្រជុំតាមទូរសព្ទ ជាមួយបុគ្គលិកជំរំ និងបុគ្គលិកសាលា ដើម្បីដោះស្រាយបញ្ហាអាកប្បកិរិយានោះ។ ឪពុកម្តាយ នឹងទទួលការប្រជុំតាមទូរសព្ទ ជាមួយបុគ្គលិកជំរំ និង បុគ្គលិកសាលា ដើម្បីដោះស្រាយបញ្ហាអាកប្បកិរិយា ហើយអាកប្បកិរិយាធ្ងន់ធ្ងរកាន់តែធំជាងនេះ នឹងបណ្តាលឱ្យមានការដកឈ្មោះចេញពីការបោះជំរំ។ វិធានការណ៍ទី 3។*

***ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន -*** *ចំពោះសិស្សដែលមិនអាចគោរពតាមវិន័យបាន ឬធ្វើឱ្យមានការប៉ះពាល់មិនល្អដល់បទពិសោធន៍របស់កុមារដទៃទៀត គឺប្រហែលនឹងបាត់បង់អភ័យឯកសិទ្ធិ ឬការប្រើប្រាស់មួយរយៈពេល ក្នុងការប្រើឧបករណ៍ជាក់លាក់មួយចំនួន។  បើសិស្សនៅតែបន្តមានបញ្ហាក្នុងការគោរពតាមវិន័យ និងអាកប្បកិរិយាយដែលបានរំពឹងទុក គឺប្រហែលនឹងត្រូវគេបដិសេធមិនឱ្យចូលរួមជាបន្តទៀត និងត្រូវគេបញ្ជូនត្រឡប់ទៅផ្ទះវិញ។*  ***មាតាបិតានឹងទទួលខុសត្រូវក្នុងការមកជំរំ ដើម្បីដកយកកូនរបស់ខ្លួនត្រឡប់ទៅផ្ទះវិញ។***

## <u>ការរំលោភបំពានលើកុមារ</u>

*បុគ្គលិករបស់មន្ទីរអប់រំ LBUSD និងរបស់ Camp Oakes YMCA ទាំងអស់ ត្រូវបានកំណត់ដោយច្បាប់ ក្នុងការរាយការណ៍ភ្លាមៗទៅអាជ្ញាធរសមស្រប អំពីរាល់ករណីសង្ស័យរំលោភបំពានលើកុមារដែលទាំងឡាយ (រួមាន៖ ផ្នែករាងកាយ ផ្លូវចិត្ត ឬ ក្បសម្ពី និង/ឬ ការមិនយកចិត្តទុកដាក់ចំពោះកូន)។*

# បញ្ជីត្រួតពិនិត្យសំរាប់សិស្សផ្ទៀងផ្ទាត់មើល មុនចេញដំណើរបោះជំរំសិក្សា

**រៀបចំទុកជាមុន៖**

_____ បំពេញបែបបទ និងព័ត៌មានទាំងអស់តាមប្រព័ន្ធអនឡាញ រួមទាំងកម្រងសំណួរអំពីជំរំសិក្សា ទម្រង់បែបបទអំពីប្រវត្តិសុខភាពរបស់សិស្ស និងបែបបទយល់ព្រមជាច្រើន។

_____ ត្រួតពិនិត្យតាមដានសុខភាពរបស់សិស្សជារៀងរាល់ថ្ងៃ មុននឹងដល់ពេលចេញដំណើរ។ សិស្សនឹងមិនអាចចូលរួមបានទេ បើមានបញ្ហាសុខភាពណាមួយដែលមិនស្របនឹងលក្ខណទាមទារក្នុងការស្នាក់នៅក្នុងជំរំ រួមមាន៖ កន្ទួលរមាស់ដែលមិនបានធ្វើរោគវិនិច្ឆ័យ ចៃ/ពងចៃ ជំងឺឆ្លងផ្សេងៗទៀត។

_____ **ថ្នាំទាំងឡាយត្រូវតែផ្តល់ដោយគិលានុប្បដ្ឋាយិកាសាលា ដែលមាន**បង្ហាញឈ្មោះសិស្ស ព្រមទាំងឯកសារដែលម្រូវឱ្យមាន នៅក្នុងសប្តាហ៍មុនពេលបោះជំរំ។

**ថ្ងៃចេញដំណើរ៖**

_____ សូមយកវ៉ាលីដែលបានវិចខ្ចប់ ប្រដាប់ក្រាលគេង និងឧបករណ៍ផ្សេងៗ ដែលមានដាក់ឈ្មោះរបស់សិស្សសំគាល់ឱ្យបានច្បាស់លាស់។

_____ សិស្សទាំងអស់នឹងត្រូវគេត្រួតពិនិត្យរកមើល ក្រែងមានស្ថានភាពជំងឺឆ្លងណាមួយ (ឧ៖ គ្រុនក្តៅ ឈឺបំពង់ក កន្ទួលរមាស់ ចៃ/ពងចៃ)។

_____ **ថ្នាំទាំងឡាយប្រហែលមិនអនុញ្ញាតិឱ្យខ្ចប់ជាមួយមសម្ភារៈប្រដាប់ប្រដាបោះជំរំរបស់សិស្សឡើយ។** រាល់ថ្នាំទាំងអស់ ត្រូវតែផ្តល់ទៅឱ្យគិលានុបដ្ឋាយការសាលា ក្នុងសប្តាហ៍មុនពេលចេញដំណើរ។

_____ ស្លៀកខោជើងវែង (មិនមែនខោយឺតជើងវែងនោះទេ) និងស្បែកជើងជាប់មាំ ដើម្បីដើរ ឬដើរឡើងទួលឱ្យបាននឹងល្អ។

## <u>បញ្ជីរៀបវេចខ្ចប់សំរាប់បោះជំរំ</u>

***ត្រូវប្រាកដថា ឈ្មោះអ្នក និងឈ្មោះសាលារៀន គឺសរសេរច្បាស់ និងងាយមើលឃើញ នៅលើគ្រប់វ៉ាលីសទាំងអស់។***

សិស្សទាំងឡាយអាចយកវ៉ាលីទៅបានចំនួន 3៖

1) កាតាបស្ពាយតូច (ប្រភេទកាតាបដែលមានខ្សែទាញចងរឹត គឺល្អ) សំរាប់យកទៅជាមួយនៅតាមឡាន ប៊ីស
2) វ៉ាលីសំរាប់ដាក់សំលៀកបំពាក់ ឬការបូបយួរ ដែលដាក់សំលៀកបំពាក់ភាគច្រើន
3) កំរាលក្រាលរមូរសំរាប់គេង ឬ កំរាលគេងបែបថង់

*សិស្សគួរតែអាចកាន់វ៉ាលីសទាំង 3 បានដោយខ្លួនឯង ចេញពីឡានប៊ីស ទៅកន្លែងកាប៊ីនស្នាក់នៅរបស់ពួកគេ*

**វ៉ាលី #1៖ ប្រភេទកាតាបស្ពៀយទៅសាលារៀនខ្នាតតូច -** ស្ពៀយកាតាបនេះជាប់ខ្លួននៅលើឡានប៊ីស កាតាបនេះគួរតែនៅជាប់ខ្លួនអ្នកគ្រប់ពេលទាំងអស់

- ដបទឹក ដែលមានឈ្មោះអ្នក
- ស្រោមដៃកក់ក្តៅ
- អាវរងារពាក់រងារឱ្យកក់ក្តៅ
- អាវយឺតដៃវែង
- ពិលតូច
- ស្រោមជើងបន្ថែមច្រើនគូ
- អាវរងារកក់ក្តៅល្មម ដែកខិត/ប៊ុនចូ (ទប់ខ្យល់ និងការជ្រាបទឹក)
- មួកសំរាប់ពាក់រដូវរងារ

**វ៉ាលី #2៖ កម្រាលគេងបែបថង់ ឬ កំរាលគេងរមូរ - អាចយកប្រើប្រាស់បាន បន្ទាប់ពីអាហារពេលល្ងាច**

ខ្នើយមួយ និង កម្រាលគេងមួយ ដាក់ចូលក្នុងថង់ធំមួយ (សំរាប់ការពារអាកាសធាតុ)។ មានបិតឈ្មោះនិង សាលារបស់សិស្សអ្នកនៅលើថង់នោះ។ កម្រាល និង ភួយក្រាស់អាចអនុញ្ញាតិឱ្យប្រើបានជាកម្រាលគេងផងដែរ។

**វ៉ាលី #3: វ៉ាលី/កាបូបដាក់សំលៀកបំពាក់ - អាចយកប្រើប្រាស់បាន បន្ទាប់ពីអាហារពេលល្ងាច**

សូមជូនយោបល់ ឱ្យដាក់សម្ភារៈអនាម័យនៅក្នុងស្បោង ziploc ធំមួយ។

**របស់ប្រើប្រាស់ចាំបាច់៖**

______ ប្រេង/ក្រែមលាបមាត់ឱ្យមានសំណើម

______ ស្បែកជើង (ចំនួន 2គូរ) ត្រូវតែមានគុណៈបាំងបិតម្រាមជើងឱ្យជិត

______ ខោជើងវែង (មិនមែនខោខ្លី ឬ យឺតទេ) (ចំនួន 3)

______ អាវរងារកក់ក្តៅល្មម បែបចាខិត (ចំនួន 1)

______ អាវយឺត (ចំនួន 5)

______ ស្រោមដៃកក់ក្តៅ

______ មួក ប៊ីនី (ចំនួន 1)

______ ស្រោមជើង (ធ្វើអំពីកប្បាស់ ឬឡែន តាមចូលចិត្ត) (ចំនួន 6-8គូ)

______ ថ្នាំដុសធ្មេញ និង ច្រាសដុសធ្មេញ

______ ក្រាសសិតសក់

______ ប្រេង/ឡេការពារកំដៅថ្ងៃ (គ្មានជាតិ អ៊ែរ៉ូសល)

______ ស្បែកជើងពាក់ងូតទឹក

______ អាវរងារយឺត (ចំនួន 2)

______ សំលៀកបំពាក់គេងដែលកក់ក្តៅ

______ អាវរងារដៃវែងចំនួន (2)

______ ខោទ្រនាប់ (ចំនួន 8)

______ ប្រដាប់បំបាត់ក្លិន (គ្មានជាតិ អ៊ែរូសល)

______ មួកមានរបាំងថ្ងៃ (ចំនួន 1)

______ សាប៊ូដុសខ្លួន និង សាប៊ូកក់សក់

______ កន្សែងពោះគោ និង ក្រណាត់ដុសក្អែល

**របស់ជាជម្រើស (យក ឬ មិនយក) ក៏បាន៖**

______ ថង់សំរាប់ដាក់ខោអាវបោក (ខោអាវប្រឡាក់កខ្វក់)

______ ម៉ាស៊ីនថត (ប្រើហើយបោះចោលបាន)

______ វ៉ែនតាការពារពន្លឺថ្ងៃ

______ សៀវភៅអាន

______ តុក្កតាសត្វសំរាប់គេងអោប

*នៅពេលខ្លះ មានធាតុត្រជាក់ខ្លាំងណាស់នៅឯកន្លែងបោះជំរំសិក្សា។ ដូច្នេះ យើងសូមលើកទឹកចិត្តឱ្យអ្នកផ្តោតលើការយកសំលៀកបំពាក់ណាដែលអាចពាក់ច្រើនជាន់បាន។ វិធីសាស្ត្រនេះ ធ្វើឱ្យអ្នកអាចពាក់អាវមួយជាន់ថែមទៀតនៅពេលដែលរងារ និងដោះអាវមួយជាន់ចេញវិញនៅពេលដែលក្តៅ ដើម្បីជៀសវាងការត្អូញត្អែរថា «ខ្ញុំក្តៅណាស់ដោយពាក់ពាក់អាវក្រាស់ពេក ប៉ុន្តែខ្ញុំរងារនៅពេលណាខ្ញុំដោះអាវចេញ»។*

*សិស្ស គួរតែអាចពាក់អាវបានដល់ទៅ 5ជាន់ (ខោទ្រនាប់ក្នុងជើងវែង អាវយឺតដៃវែងក្រាស់ អាវរងា និងអាវពាក់ការពារទឹកភ្លៀង/ខ្យល់) ហើយ ស្លៀកខោ 2ជាន់ លើដងខ្លួនផ្នែកខាងក្រោម (ខោទ្រនាប់ក្នុងជើងវែង និង ខោជើងវែងដែលកក់ក្តៅ)។*

*សូមចំណាំថា គឺមានភាពខុសគ្នាយ៉ាងខ្លាំងរវាង អាវរងារ ឬអាវប៉ុនចូ ដែលការពារកុំឱ្យទឹកជ្រាបសើម (waterproof) និងអាវដែលគ្រាន់តែធន់នឹងទឹក (water resistant)។ ប្រសិនបើលោកអ្នក ឱ្យកូនដែលពាក់អាវដែលគ្រាន់តែធន់នឹងទឹកមកនោះ គឺទឹកនឹងជ្រាបសើមទទឹកអាវជោគយ៉ាងឆាប់រហ័ស ហើយពួកគេនឹងរងារ ហើយទទឹកសើមខ្លួនជោគជាមិនខាន!*

***សូមកុំភ្លេចសរសេរឈ្មោះអ្នក និងឈ្មោះសាលារៀននៅលើរបស់ប្រើប្រាស់គ្រប់យ៉ាងទាំងអស់។**
**មន្ទីរអប់រំ LBUSD និង ជំរំ YMCA CAMP OAKES មិនទទួលខុសត្រូវចំពោះរបស់ប្រើប្រាស់ ដែលបាត់បង់ ឬត្រូវគេលួចឡើយ។**
**យើងខ្ញុំនឹងព្យាយាមប្រគល់រាល់របស់របរដែលបានរកឃើញទាំងនោះត្រឡប់ទៅឱ្យម្ចាស់ដើមវិញ។***